# NEWS RELEASE

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១

## *សេចក្តីព្រាងច្បាប់NGO របស់កម្ពុជា ត្រូវតែស្របទាំងស្រុងតាមច្បាប់អន្តរជាតិ–អ្នកជំនាញការ អ.ស.ប មានប្រសាសន៍*

**ទីក្រុងហ្សឺណែវ**–អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពខាងការប្រជុំដោយសន្តិវិធី និងខាងសមាគម លោក ម៉ៃណាគីអៃ បានប្រមានថា សេចក្តីព្រាងជាសាធារណៈបច្ចុប្បន្ននៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ប្រសិនជាច្បាប់នេះត្រូវបានអនុម័តនោះ វានឹងមានហានិភ័យរំលោភបំពានលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

"សេចក្តីព្រាងច្បាប់NGOs បច្ចុប្បន្ននេះ មានបទប្បញ្ញត្តិមួយចំនួនដែលចោទជាបញ្ហា បង្កើតជាកង្វល់អំពីផលប៉ះពាល់អវិជ្ជមានចម្បងៗទៅលើការចូលរួមតាមបែបលទ្ធិប្រជាធិបតេយ្យរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការជំរុញការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន" អ្នកជំនាញការ អ.ស.ប បានកើនរំលឹកដូច្នេះ។ ដោយស្វាគមន៍សេចក្តីថ្លែងការណ៍នាពេលថ្មីៗនេះរបស់ឯកអគ្គរាជទូតកម្ពុជា ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប ដែលសន្យា "បន្តកិច្ចពិគ្រោះយោបល់" តទៅទៀត។ លោកបានអំពាវនាវឲ្យអាជ្ញាធរនានា ពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់នេះតាមរយៈកិច្ចពិគ្រោះយោបល់ដែលបើកចំហរ និងប្រកបដោយអត្ថន័យ ជាមួយសមាគម និង អង្គការNGOs នានា។

លោក គីអៃ បានគូសបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះ តម្រូវឲ្យសមាគម និង អង្គការNGOs ទាំងអស់ធ្វើការចុះបញ្ជីដោយខានមិនបាន មិនមែនឲ្យធ្វើតាមការស្ម័គ្រចិត្តនោះទេ ហើយហាមឃាត់ក្រុមផ្សេងៗដែលមិនបានចុះបញ្ជី មិនឲ្យធ្វើសកម្មភាពឡើយ។ "នេះជាការបំពានយ៉ាងច្បាស់ទៅលើសិទ្ធិសេរីភាពខាងសមាគម។ ការមានឋានៈគតិយុត្តមួយដែលគេទទួលស្គាល់ អាចផ្តល់សិទ្ធិនិងអត្ថប្រយោជន៍ដល់អង្គការទាំងឡាយ ដូចជា លទ្ធភាពក្នុងការបើកគណនីធនាគារ ប៉ុន្តែឋានៈគតិយុត្តនេះមិនមានភាពចាំបាច់សំរាប់ការទទួលបានសិទ្ធិសេរីភាព ខាងសមាគមនោះទេ"។

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

"សេចក្តីព្រាងច្បាប់នេះ រាប់បញ្ចូល ជនភៀសខ្លួន បុគ្គលគ្មានរដ្ឋ និង បុគ្គលឯទៀតដែលមិនមាននិវេសដ្ឋាននៅកម្ពុជាមិនឲ្យបង្កើតសមាគមឬអង្គការNGOsក្នុងស្រុក តាមរយៈការកំណត់សមាជិកស្ថាបនិកស្របច្បាប់ក្នុងក្រុមប្រឹក្សាភិបាលត្រូវមានសញ្ជាតិកម្ពុជា។ អ្នករាយការណ៍ពិសេសមានប្រសាសន៍ដូច្នេះ។ "ការតម្រូវអំពីសញ្ជាតិនេះ ជាការរំលោភថែមទៀតលើសេរីភាព ខាងសមាគមដែលបុគ្គលគ្រប់រូបនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គួរតែទទួលបានសិទ្ធិនេះ។"

កង្វល់ផ្សេងទៀត រួមមាន ការតម្រូវឲ្យមានសមាជិកភាពដែលមានចំនួនអប្បបរមាខ្ពស់ សំរាប់ការបង្កើតអង្គការនិងសមាគម ការខ្វះភាពច្បាស់លាស់នៃបទបញ្ញត្តិសេចក្តីព្រាងច្បាប់ដែលគ្រប់គ្រងលើលក្ខណៈវិនិច្ឆ័យសំរាប់ការចុះបញ្ជី ការព្យួរ ឬ ការបញ្ឈប់ ហើយដំណើរការចុះបញ្ជីអង្គការNGOs បរទេសមានលក្ខណៈស្មុគ្រស្មាញ និង ការិយាធិបតេយ្យខ្លាំងពេក ដែលអាចកំរិតវិសាលភាពនៃសកម្មភាពរបស់អង្គការទាំងនោះ និង ធ្វើឲ្យ ប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគេ។

"ក្របខ័ណ្ឌគតិយុត្តមួយ ដែលធានាសេរីភាពខាងសមាគម គួរតែបង្កភាពងាយស្រួល ជាជាងការត្រួតត្រាដល់ការទទួលបាននូវសិទ្ធិនេះរបស់បុគ្គល ជាផ្លូវការ ឬក្រៅផ្លូវការ "លោក គីអៃ បានកត់សំគាល់ដូច្នេះ។ "ច្បាប់នេះ គួរតែកើតចេញផងដែរ ពីដំណើរការមួយដែលបើកចំហរមានតម្លាភាពបង្ហាញពីសុឆន្ទះ និង ការជឿទុកចិត្ត។"

មានប្រសាសន៍បន្ថែមលើសេចក្តីអធិប្បាយរបស់លោក គីអៃ អ្នករាយការណ៍ពិសេសស្តីពីសេរីភាពខាងការសំដែងមតិ និងយោបល់ លោក ហ្វ្រាំង ឡារ៉ូ បានគូសបញ្ជាក់ថា " ឧបសគ្គសំរាប់ការប្រព្រឹត្តទៅប្រកបដោយឯករាជ្យ និងមានប្រសិទ្ធភាពរបស់អង្គការNGOs នៅកម្ពុជា បានលើកឡើងជាកង្វល់ផងដែរ អំពីលទ្ធភាពរបស់អ្នកការពារសិទ្ធិមនុស្ស ក្នុងការអនុវត្តន៍សិទ្ធិស្របច្បាប់របស់ខ្លួនខាងការសំដែងមតិ និងយោបល់របស់ពួកគេ។"

ដូចគ្នានេះដែរ អ្នករាយការណ៍ពិសេសរបស់ អ.ស.ប ស្តីពីអ្នកការពារសិទ្ធិមនុស្ស លោកស្រី ម៉ាហ្គារេត សេហ្កាយ៉ា បានមានប្រសាន៍ថា "ដោយឃើញពីសារៈសំខាន់នៃតួនាទីដែលអ្នកការពារសិទ្ធិមនុស្ស ត្រូវបំពេញក្នុងសង្គមប្រជាធិបតេយ្យ ការអនុវត្តន៍ពេញលេញ និងដោយសេរីនៃសិទ្ធិសេរីភាពខាងសមាគម ដាក់ការទទួលខុសត្រូវលើរដ្ឋនានា ក្នុងបង្កើតឲ្យមានបរិយាកាសងាយស្រួលសំរាប់អ្នកការពារសិទ្ធិមនុស្សដើម្បីអនុវត្តសកម្មភាពរបស់ខ្លួនដោយសេរី។

"យើងខ្ញុំសូមស្នើយ៉ាងទទូចដល់អាជ្ញាធរកម្ពុជា សូមយកមកពិនិត្យពិចារណាយ៉ាងល្អិតល្អន់អំពីកង្វល់ស្របច្បាប់ទាំងឡាយ ដែលសមាគមនិងអង្គការNGOs បានលើកឡើងម្តងហើយម្តងទៀតនៅក្នុងអំឡុងពេលកិច្ចពិគ្រោះយោបល់ជាបន្តត្រូវបានប្រកាសឲ្យដឹង អ្នកជំនាញការបានមានប្រសាសន៍ដូច្នេះ ដោយទទួលស្គាល់ថា រដ្ឋាភិបាលបានពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់នេះជាច្រើនលើកច្រើនសាររួចមកហើយ។

"យើងខ្ញុំត្រៀមខ្លួនជាស្រេច ដើម្បីផ្តល់ការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស ដើម្បីធានាឲ្យច្បាប់នេះស្របតាមបទដ្ឋានច្បាប់អន្តរជាតិ" អ្នកជំនាញការមានប្រសាសន៍បន្ថែមដូច្នេះ។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេសរបស់អ.ស.ប ស្តីពីសេរីភាពខាងសមាគម បានស្នើឲ្យមានការ

អញ្ជើញជាផ្លូវការមកកម្ពុជា ដើម្បីពិភាក្សាការងារដែលរដ្ឋាភិបាលបាននិងកំពុងខិតខំប្រឹងប្រែង ដើម្បីធានាសិទ្ធិសេរីភាពខាងការប្រជុំ និង ខាងសមាគម រាប់ទាំងសេចក្តីព្រាងច្បាប់នេះផងដែរ។

## ចប់

*អ្នករាយការណ៍ពិសេសបីរូបដែលឯករាជ្យពីរដ្ឋាភិបាលណាមួយ និងបំរើការក្នុងសមត្ថភាពផ្ទាល់ខ្លួន។*

*លោក ម៉ៃណាគីអៃ (ជនជាតិគេនយ៉ា) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប តែងតាំងក្នុងឆ្នាំ២០១១ ជាអ្នករាយការណ៍ពិសេសដំបូងគេ ស្តីសិទ្ធិសេរីភាពខាងការប្រជុំ និងការបង្កើតសមាគម។*
*http://www.ohchr.org/EN/Issues/AssemblyAssociation/Pages/SRFreedomAssemblyAssociationIndex.aspx*

*លោកស្រី ម៉ាហ្គារេត សេហ្គាយ៉ា (ជនជាតិអ៊ូហ្គាន់ដា) ត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ក្នុងមីនា ឆ្នាំ២០០៨ ។*
*.http://www.ohchr.org/EN/Issues/SRHRDefenders/Pages/SRHRDefendersIndex.aspx*

*លោក ប្រ៉ាំង ឡារូ (ជនជាតិហ្គាតេម៉ាឡា) ត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពខាងការសំដែងមតិ និងយោបល់ ក្នុងមិថុនា ឆ្នាំ២០០៨ ។*
*.http://www.ohchr.org/EN/Issues/FreedomOpinion/Pages/OpinionIndex.aspx*

*គេហទំព័រប្រទេសរបស់OHCHR – កម្ពុជា៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សំរាប់ព័ត៌មានបន្ថែម និង **ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក Guillaume Pfeifflé តាមរយៈ (ទូរស័ព្ទលេខ 41 22 917 9384 / អ៊ីម៉េល gpfeiffle@ohchr.org)*

**សិទ្ធិមនុស្សអ.ស.ប យល់ដឹងពីយើងតាមរយៈព័ត៌មានសង្គម៖**
http://www.facebook.com/unitednationshumanrights
https://twitter.com/unrightswire